# ច្បាប់កិរកាលថ្មី

ពាក្យកាព្យរបស់ព្រះភិរម្យភាសា អ៊ូហៅង៉ុយ

## រៀបរៀង

នេះបទព្រហ្មប្រាជ្ញប្រាយ ខ្ញុំអធិប្បាយលើកល្បត់ល្បង ប្រដៅកូនចៅផង បងជាច្បាប់ខុសនឹងត្រូវ ។ កត្តិកម្មើត គ្រូគ្មាន ក្នុងវិសត្ដរដ្ឋូរ ទឹកស្រែជន់លិចស្រូវ នៅសំណល់ សំណាបថ្មី ។ កិរកាលពីព្រេងព្រឹល ដើមគំនិតពិសេដ្ឋ ខ្ញុំលើកកិរកាលថ្មី បែងសេចក្ដីជាបរមត្ថ ។ ក្នុងថ្ងៃពេញបូណ៌-មី ម៉ោង ៨ ព្រលប់ស្ងាត់ ឆ្នាំបបត្វាក្សត្រ· ផាត់សក្រាជ កន្លងផ្លាយ ។ សាស្នាព្រះសមណ បាន ២៤០០ ប្លាយ ៦៥ ចាំចាយ ចាត់អធិប្បាយពីខុសត្រូវ ។ កិរកាលដំណាល ទុក ជាទំនុកដំណាលនៅ ដំណតរៀងទៅ ជម្រិបចិត្តជន ប្រុសស្រី ។ កូនខ្មើយពាក្យអាពុក ជាទំនុកទំនើបថ្មី អនិស្រាយ រាយបារ្មី អាពុកស្ដីឲ្យកូនស្ដាប់ ។ គួរស្ដាយកេរ្ដិ៍មែឪ កិរិយាត្រូវឲ្យខំត្រាប់ កិរិយាណាខុសច្បាប់ គួរក្រឡាប់ក្រ-

ឡូះហោល ។ ម្ដាយអាពុកនឹងកូន បើដូចខ្លួននឹងស្រីមោល ឃើញខុសកុំដេញដោល កុំហ្កោលទោសអ្នកមានគុណ ។ ល្ងង់ខ្លៅត្រូវតែសួរ ពាក្យឲ្យគួរកុំឲ្យស៊ុន យកពាក្យផ្អែមជាមុន ទន់លំទោនឪនប្រតិបត្តិ ។ ទោះម៉ែឪស្លូតកាច គួរតែខ្លាចដូចមហាក្សត្រ ម្ដាយដេរពីរបីម៉ាត់ គួរតែស្ងាត់ស្ងៀមឲ្យឈឹង ប្រដៅត្រូវតែស្ដាប់ យកជម្រាប់កុំទទឹង ម្នោម្នះបបេសរឹង នឹងហើយហៅកូនសេសកម្ម ។ ធម៌អាប៉ីបេះតែភ្លេច ជេរប្រទេចបេះតែចាំ អាពុកពត់ទៅស្ដាំ អកុសលកម្មទាញទៅឆ្វេង ។ អវិជាតបុត្រ ខូចបំផុតតាំងពីក្មេង ប្រព្រឹត្តព្រើលផ្សេង ៗ បើលេងអ្វីស្ដីមិនស្ដាប់ ។ មិនស្ដាយជាតិកំណើត ល្ងង់ស្លូតស្លើតដល់ចាស់ស្លាប់ ត្រឹមត្រូវមិនស្ងៀវស្ដាប់ ព្រួយគេប្រាប់ទាំងយប់ថ្ងៃ ។ អ៊ែឪមានគុណណាស់ មិនសំពះខ្មាសអៀនដៃ បើអ្នកក្រៅដទៃ វិស័យសោះសំពះបាន ៗ ឆ្លើយបាទបាះបាំខ្ញុំ រាបរម្យទំនឹងសន្ដាន ម៉ែឪឯងក្នុងឋាន បានឆ្លើយអឺអាញ់អឺអើ ។ អនុជាតបុត្រ ស្លូតបំផុតស្រណុកប្រើ ប្រសប់ការប្រសើរ ដើរតែតាមលំអានឪ ។ ប្រដៅទទួលយក បេះ

សែលកស្គាល់ខុសត្រូវ ស្រណុកញាក់ធ្លាក់ផ្លូវ មិនសួរក្លេបឯម្ប្បន្នាន ។ អតិជាតបុត្រ ល្អបរិសុទ្ធស្គាល់សីលទាន នាំឳទៅនិព្វាន ឈានទៅរកកន្លែងសុខ ។ បេះលើសៈគឯរាបជឿបុណ្យបាបប្រែតនរក មិនល្មោភនឹងម៉ួតល្មក់ ភ័យនឹងភក់ភពសង្សារ ។ នេះគឺដើមបាឡី បុត្រទាំងបីបែបកិរិយា ស្រឡាញ់ណាស្អប់ណា តាមសញ្ញាចូលបិត្តបុះ ។ អវិជ្ជាក់ផ្លូវក្រោម ប្រព្រឹត្តព្រមតែខាងខុស អតិជាតមារយាទខ្ពស់ អនុនោះយ៉ាងកណ្តាល ។ អតិ ១០០ មាន ១ គួរតែស្ទួយដាក់លើក្បាល អវិគឺស្រើបស្រាល ត្រអាលយកតែពីរយ៉ាង ។ អតិជាតិកំណើត គំនិតកើតពីកសាង កុសលដម្កល់ខាងសំណាងកើតពីគំនិត ។ អនុអានាងអើយ ខ្លួនធំហើយឪឡ្យបេះគិត បេះកាញ់ស្គាល់ឆ្ងាយជិត ប្រព្រឹត្តយកតែខាងត្រូវ ។ រៀនរិះរកទ្រព្យធន យកប្រពន្ធមើលធុនឪ ធុនហោកជ្រិកខុសផ្លូវ អ្នកកុំទៅខ្លាចបន្លា ។ ផ្លូវវៀចកុំបោះបង់ ផ្លូវព្រៃត្រង់កុំយាត្រា ឈានឈរពិចារណា ឆ្ការឡ្យស្អាតសុំដើរទៅ ។ កុំដើរភ្លើភ្លេបខ្លួន ខ្លាចក្រែងជួនធ្លាក់ជ្រោះជ្រៅ ជ្រកម្លប់សំ-

ណាក់នៅ កុំបោះពៅផ្កាប់គល់ឈើ ។ ធេះខ្វេះបសំបកក្រោម
ស្រះពោនញមស្មោកស្លឹកលើ មានភ្នែកឲ្យបេះមើរ កុំល្ងេល្ងើ
ល្ងង់ល្ងិតពេក ។ រៀនដើរឲ្យមើលផ្លូវ ផ្ញើស្រែស្រូវឲ្យមើល
មេឃ ម្លប់ឆ្លកធ្លាប់ជ្រិកដេក ជាជំះណាកអ្នកដំណើរ ។
ដំណែលដែលគេដាក់ ជាជំណាក់ទំនួលផ្ញើ បំពរាំបាំគ្រាន់ពើ
ដើរក្រោយ ៗ គ្រាន់ជ្រិកទៀត ។ ឈើណាទោសសត្រូវ ជុះ
ជីតផ្លូវនាំបង្អៀត ជំពប់យប់អាធ្រាត្រ ធ្លៀតកាប់បេញកុំទុកវា ។
បន្លាគល់ជង្គត់ កន្លងផុតតែភ្នែកជា ដើរឃប់ជំពប់ពា ក្រែង
គ្រោះគ្នាអ្នកដើរក្រោយ ។ គ្នាមុតកុំបាំផ្កាន់ ឃើញគួរជាន់កុំ
បណ្ដោយ បណ្ដើរមើលខ្លាំងខ្សោយ ឲ្យពិនិត្យពិចារណា ។
ពាក្យពិតត្រង់ប្រាកដ ត្រូវប្រើនបទប្រើនប្រការ ប្រកបជា
ប្រស្នា ប្រាជ្ញាអាប់ស្លាប់នឹងធ្លល់ ។ ផ្លូវពិតទាំងជិតឆ្ងាយ
សព្វសុះសាយមិនសេសសល់ អ្នកណាប្រាជ្ញាដល់ ដឹងយោ
បល់ព្រើទកន្លែង ។ ក្លន្មើយការកេរ្តិ៍ឈ្មោះ កុំបង់រស់តែម្នាក់
ឯង គិតអ្វីគិតឲ្យវែង ក្រែងក្រក្រោយសិយគំនិត ។ កំណើត
រាល់រូបកាយ បេញផ្លួញឆ្ងាយស្ដាយផ្លួញជិត ពិញ្ញមជន្មជីវិត

គិតឡស្រេបៈទីបបានស្រួល ។ ធ្វើស្រែបង់បានស្រូវ ដើមរង្វើរ ធ្វើស្រែទួល ស្រែទាប.មើលទំនួល លើកទំនប់ឲ្យមាំមួន. ។ កូនឡើយកើតមេបា ចាំរក្សាមើលថែបួន ធុញជប់ជ័យៈហ៊ាកខ្លួន ដ្ឋូនជាខ្សត់គេហ៊ាខ្ញោយ ។ ស្រូវខ្សោយអង្ករថ្លៃ លក់សំបៃ ទុកឆ្នាំក្រោយ អ្នកក្ររកញយ ៗ ឲ្យអ្នកសុំជាងអ្នកខ្ចី ។ សប្បុរសពេកបំយធន មួរខ្ញូរជនបំយរាសី ប្រពន្ធល្អច្រើនអាប់ ប្ដី ពាក្យអប្រិយបាញ់អាត្មា ។ ឈើផ្លែបាញ់សន្លឹក ត្រីរេរឹក ទឹកមិនថ្លា កំណាញ់ក្រៅដម្រា សោតសឹងអាប់ប្រយោជន៍ យស ។ នឹងឲ្យៗមើលភាព ឲ្យអ្នកទាបជាងអ្នកខ្ពស់ អ្នក ទិញឈប់សិនចុះ ក្នុងតែរស់មិនស្លាប់ងាយ ។ កំណាញ់ហួស កំណត់ ពាក្យអ្នកខ្សត់ខ្វះបនិយាយ ទេវតាផ្ដន្ទាទៈយ រលាយ អស់រលោះឯង ។ សទ្ធាមើលធនធាន ជាតិអ្នកមានមិនអៈង្វង់ កំណាញ់ដោយកន្លែង ក្រែងគ្រោះក្រដល់ឆ្នាំក្រោយ ។ អ្នក ក្រខ្ចីនេះកុំ អ្នកមានសំនេះគួរឡ អ្នកប្រាជ្ញអង្គាសញយ អស់ ក៏ដោយឡទៅចុះ ។ អ្នកក្របានជាហោម ពីបាកតាមទៅឯ ណោះ ទាល់ទឹកចូលច្រមុះ ច្រើន.កីត.ឈ្លោះពីព្រោះយល់ ។

អ្នកមានគេមាំនខ្មាស សងរហ័សមិនអំពល់ ដូនយើងមាន រវល់ គេស្គាល់មុខស្រណុកខ្ញុំ ។ អ្នកក្រ ៗ ទាំងចិត្ត ស្រូវ ផ្នារល្អិតឲ្យមើលល្អ រាល់ល្អកក្ដាំងបី ទាន់ស្រូវថ្មីទាធាប់បាន ។ បូនក្រែងឯងក្រវិញ ទោះដូរទិញមើលប្រមាណ ជឿបុលខ្ញុំ សន្តាន កុំហានពាកញ្ចើធំ ។ ខ្លួនក្រកុំបង់ធាត់ កុំងាយមាត់ អាងតែសុំ ជឿខ្ញុំល្អក្រមុំ ស្រូវឯងទុំស្រណុកសង ។ បើជឿ ខ្ញុំគេឲ្យ កុំទៅញយគេឲ្យខ្នង ខ្ញុំគេឯណោះផង កុំប្រើនដងគេ មើលងាយ ។ ក្រលុយកុំងុយដេក ចូលដំណេកកុំនិយាយ សំពត់ញាត់ស៊ុំពាយ វាយរើសរៀបញាត់សំពៀត ។ រៀបដេក សំពះគុណ កុំដេកស៊ុនឲ្យប្រុងស្នៀត ភ្លើងធេះយប់អាធ្រាត្រ កណ្ដៀតទូលប្រមូលវត់ ។ ខ្លួនវាស្ត្រក្រមាសប្រាក់ ភើបកន្ត្រាក់ អាវសំពត់ ទុំភ្លើងរលត់ ស្លៀកផ្គង់ផ្គត់សោះខ្មាសគេ ។ កូនើយគិតឲ្យគ្រប់ រៀងរាល់យប់កុំទំនេ ដាងដេកលក់ទទេ យល់សព្វដេរបីសាបក្រៅ ។ ទំលាប់មាត់មមើ ស្រែកហា យើ ៗ ឪ ៗ ហោរខ្មាំងខ្មោចចិត្តខ្មៅ ហៅមេខ្មែរវ៉ៃឲ្យខ្មុក ។ ដេកផ្អៀងដាងអង្គុយ ល្ងាល្ងាន់ល្ងុយកុំទ្រាំងក់ ពីល្ងាបដេក

ឲ្យលក់ មាន់ល្មោរិដក់ស៊ីម្ជស្លា ។ ដាំងល្វិតឥតអំពើ ឥត អ្វីធ្វើស្ងូត្រធម៌អាថ៌ បើច្បាស់រិបស្សនា សូក្ខស្មាធ៌ស្និះប្រឹងឲ្យ ស្មោះ ។ គង់ទ្វើយដេកកើយស្មុក គ្រប់ឲ្យសុខស្ងូត្រអម្បោះ កុំដាក់ដោយគៀនកោះ អស់នឹងសត្វកណ្ដៀកោរ ។ កណ្ដូរ កន្ទាតកាត់ ដប់កំណាត់ខានដេរខោ ជួនកាលមានអាហោរ លលបល្លបលីទៅបាត់ ។ កុំដាក់ឆ្ងាយប្រយោល ទុកជា ហោលមិនប្រយ័ត្ន ប្រយោជន៍យប់យាមស្ងាត់ បង្កាត់ភ្លើង បង្គោលគោ ។ បង្ការក្រែងមូសខាំ ត្រូវបំណាំខ្យល់ជុំនោរ បាយកកផ្អកផ្អូមៈដារ ឲ្យអាលោស៊ីបាំសេះ ។ កំណើតផ្ដែ ញីឈ្មោល ដេកបំណុលតែនឹងផេះ រៀនប្រើមើលបំណោះ រិះបំណាំតាមកិរិយា ។ ទោះប្រើកូនតូចធំ ឬប្រើខ្ញុំឲ្យធ្វើការ ធ្វើកល់យល់ប្រាជ្ញា អាណាហាន់ប្រើទៅឆ្ងាយ ។ អាខ្លាប ប្រើតែជិត ឥតគំនិតប្រើរៀងអាយ ខុសអង្គកុំដេរម្ដាយ ពេល ដល់បាយកុំនាំឈ្មោះ ។ មនុស្សឃ្លានវាហានឆ្លើយ ស៊ីរួច ហើយបន្ទោសបុះ បាយឆ្អែតប៉េងពេញពោះ ស្ដីខុសត្រូវមិន ស្ងូវខឹង ។ កូនឆ្មើយពាក្យអាពុក បំណាំទុកពីត្រឹមណឹង ធ្វើ

ប្រុសឡេះប្រឹង រៀនឡេងឹងស្គាល់ពុតស្រី មារយាទនឹងមារយា ម្យ៉ាងចិត្តជាបេះដូងប្ដី ខ្លុះស្លាប់រស់រាហ៎ យកពីរបីនេះនេះមិនបាន ។ កុំលោភច្រើន ៗ ព្រួយ យកតែមួយសុខក្សេមក្សាន្ត ចិត្តស្រីទាំងប៉ុន្មាន បានប្រមូលមៅមិនខុស ។ មិនខ្វបគ្រប់តែស្រី ល្អពីរបីជឿចាំបុះ ជាតិស្រីលោភលើសប្រុស នោះមិនខុសស្រីណាមួយ ។ ខ្លាំងខ្សោយកុំឡេខ្វល់ទោះតឿយហត់កុំលំអួយ ធ្វើប្រុសតែងតែព្រួយ ស្រីមិនជួយកុំថ្មីញថ្លៃ ។ ខ្លួនខ្លាំងកុំគិតខ្លាប ស្រី ៗ កាចស្លូតដោយខែរដូវធ្វើស្រូវស្រែ បែបប៉ប្រែស្ដីលើប្រុស ។ ខែស្ហួងនឹងខែប្រាំកាចរហូតដល់ខែបុស្ស ខែបែនរបោករលោះ រលីងអស់អំពីដី ។ ជញ្ជូនដាក់បង្រុក ពូជពេញទុកស្បោងពីរបី ដំណើបបូនដប់ល្អី ស្រី ៗ ស្លូតហើយខែទឹង ។ ស្លូតឆ្គុតនៅខែមាឃ ស្ដីធ្ងន់ពាក្យមិនស្ងួរខឹង បើប្រុស ៗ មិនដឹង ប្រឹងតែប្រួតស្អប់ស្រី ៗ ។ ម្យ៉ាងរឿងមារយាទខ្វប មារយាបេះក្រូបដកខ្ញីមានប្រុសសាហាយថ្មី រិតថ្នមប្ដីមិនឡេអាក់ ។ អឺ អឺតែមាត់ក្រៅ ចិត្តមួមៅគ្មានត្រីដាក់ ត្រីសាប់ល្អល្អបលាក់ ដាក់តែ

ឆ្អឹងឡូងងសុី ។ បញ្ចោះបះបញ្ជើ បញ្ជោតប្រើងងវក់វី វឹក ប្រួតប្រុសពីរ សុីទាល់ងាប់គាប់សងខាង ។ មួយទៀតផិតកុំឡោះ ស្រឡាញ់ស្មោះស្មគ្រអស់យ៉ាង លោមប្ដីលាសំណាង ទាស់ ក្អេងក្អាងទាសំរេត្រ ។ បើប្ដីមិនព្រមលែង លបដំទែងជំទយ វត់ មួយទៀតខូចបំផុត មត់ឡប្រុសសម្លាប់ប្ដី ។ ម្យ៉ាងទៀត មារយាទផា មានច្រើនគ្នាក្នុងលោកិយ៍ ប្រាកដពេញជាស្រី ប្រុសភីរបីស្នាលាកម្ម ។ ស្លាប់រស់មួយនឹងមួយ មិនបង់ព្រួយ យកប្រុស ៥ ប្ដីស្លាប់បួនដប់ឆ្នាំ ចាំសីលទានមិនមានទៀត ។ ធ្វើព្រេណ្យផ្សងសព្វ សុំប្រាថ្នាជួបរាល់ជាតិ អុបធូបដេកទប ជាតុ កណ្ដៀតហោកោរកាន់ទុក្ខ ។ និយាយពីពុតប្រុស បួរចាំ ចុះជាទំនុក ដំណាតទៅមុខ អាពុកប្រាប់ឡស្រីចាំ ។ ប្រពន្ធ មួយមិនស្កប់ ប្រពន្ធដប់គ្រាន់តែស្កាំ កាបស្លូតរហូតឆ្នាំ រាំដរាប រាល់រូបា ។ កាបម្យ៉ាងខាងល្បាបព្រឹក រឿងបាយទឹកញ៉ាំមូស្លា ក.បម្យ៉ាងៈរឿងៈធ្វើការ ម្យ៉ាងទៀតណារឿងប្រពាន់ ។ ព្រជុំជាតិ ចិត្តប្រុស ត្រូវនឹងខុសដោយបេកំណក់ គំនិតល្អសំខាន់ ប្រកាន់ មើលតិរិយាបថ.។ ប្រមាន់ភាវរាល់ឈ្មោះ ច្រើនកើតឈ្លោះទៅ

ដាខ្សត់ មួយឃើញដាក់ប្រាកដ ប្រកៀកចាប់ធ្វើទោសបាន ។
លក់លៃតែខាងប្រុស ប្រពន្ធខុសបង្អង់ខាន ខូចអួងខាតប៉ុន្មាន
រាប់អានឱបក្រសោបទៀត ។ មួយលក់លៃទាំងពីរ នៅរកស៊ី
ដោយសារញាតិ ស្រីមារយាទឥតមារយាទ ស្មាលាជាតិមិន
ឡប្លន ។ ប្រចាន់ទាំងបីបទ គួរគួបកត់ទុកក្នុងខ្លួន លក់
ពីរពេញបំនួន កូនគំទុកយកជាច្បាប់ ។ ប្រចាន់ហើយយក
ទៀត ហៅជូជាតិមារយាទអាប់ កូនណាយកដំរាប់ ស្លាប់
នឹងស្រី ៗមើលងាយ ។ ទោសតិបកុំទាញផ្សំ ពរះញមិន
បំកុំនិយាយ ៖កុំចាប់ស្មើររើរវាយ នាំឲ្យរវល់អំពល់ចិត្ត ។
ពុតប្រុសនឹងពុតស្រី ចប់សេចក្តីពីក្បត់ផិត រើសរឿងណា
សុចរិត គិតសំគាល់រាល់រូបកាយ ។ បើមានកូនក្រមុំ គួរ
តែកុំបណ្តោយឆ្ងាយ ឲ្យមើលនាយមើលអាយេ ស្រេបគួរម្តាយ
រក្សាកូន ។ ប្រយ័ត្នកុំឲ្យឃ្លាត ភ្លាត់មារយាទមិនសុទ្ធសូន្យ
កុំទុកចិត្តបងប្អូន ដ៏ដូន ១ ជួយរក្សា ។ ក្រមុំមានម្រាក់មិត្រ
មេមួយគិតនាំកិច្ចការ កុំជឿចិត្តអ្នកណា មើលកិរិយារបស់
កូនឯង ។ ទោះស្នួងដកយប់ថ្ងៃ ះដើរយកដៃដាប់សង្វៀង

ប្រុសខូចល្បួបបន្ទែង តែទាស់ភ្នែកបែកមេបា ។ ច្រើន
ណាស់តែសែនខ្មោច កេរ្តិ៍អាសោចខូចអាសា នាំកូនឡើង
សាលា គេថាឲ្យជម្ងឺចិត្ត ។ បើមានកូនប្រុសា មិនទាន់
ការគួរឲ្យប្រិត កុំឲ្យបំរើផ្អិត អាណិតរ៉ា ៗ សងគុណ ។
យប់ថ្ងៃចូលប្រតិបត្តិ គាតក្រវាត់រត់រែកពុន អានឹងច្រើន
ជឿមុន សុំនអំពីអាពុកម្តាយ ។ រក្សាកូនប្រពន្ធ រកទ្រព្យ
ធនបង់ធូរបាយ ផ្ចិតជិតគំនិតឆ្ងាយ ផ្ចិតរៀងអាយរក្សា
គុណ ។ អំពើបាបកុំរៀន កុំអៀនប្រៀនក្នុងការបុណ្យ
លាងទោសៈបញ្ជាមុន ទើបធ្វើបុណ្យបំរើនផល ។ បើនឹង
បង់គង់ទ្រព្យ កុំទំលាប់សាងអកុសល ល្បិញល្បួញរៀប
កាបកល់ ទេវតាបួលប្លេចធនធាន ។ កុំឈ្នានិះអ្នកខ្សត់
កុំបំភ្លាត់ទ្រព្យអ្នកមាន បើខ្លួនខ្សត់អត់ឃ្លាន រៀនតែរកតាម
ទៀងត្រង់ ។ ផ្ចិតខាតកុំឈប់ខាន បើចង់បានកុំខ្លាចបង់
ខ្លាចបាត់ឲ្យផ្ចិតផ្ចង់ ប្រុងថែទាំឲ្យមាំមួន ។ កុំភ្លើធ្វើជា
ភ្លេច ភ្លាត់បន្តិចខ្លាចក្រែងបួន ក្រែងចោរចូលមកពួន លួច
លបលួចយកទ្រព្យទៅ ។ ប្រហែះតែងតែបាត់ ប្រុង

ប្រយ័ត្នតែងតែនៅ គិតសព្វគ្រប់ដោយផ្លូវ ស្លូវទ្រាំតៀយ
កុំទ្រាំក្រ ។ នៅផ្ទះស្រះរបង របាបងឲ្យជាល្អ ប្រើប្រាស
ខ្ញុំកំដ ឲ្យបរិភោគដោយខ្លួនឯង ។ នឹងប្រើទៅហៅមក
កុំកំហិកយកកំហែង កុំបារឡើងហាងឯង ក្រែងកំហល់ទល់
កំហឹង ។ កុំហួសពាក្យសំដី ការអ្វី ៗ ឲ្យរបះប្លឹង កុំប្រើ
ប្រួតពៅប្រឹង ក្រែងកើតខឹងវានាំខាត ។ មនុស្សខឹងច្រើន ៗ
ខុស មនុស្សច្រើនឈ្លោះច្រើនប្រមាទ ការល្អច្រើនត្រូវខ្នាត
បើចង់ស្អាតកុំខ្លាចយូរ ។ ចង់ប្រាជ្ញឲ្យខំប្រឹង បងក្បិនតឹងរក
ស៊ីធូរ គំនិតមុនគំនូរ រៀនមានគ្រូមានគេរាប់ ។ បំរើឪពុក
ម្តាយ អ្នកនៅឆ្ងាយគេច្រើនគាប់ អ្នកណាបំរើខ្ជាប់ ផ្លាប់តែ
ខុសមិនដែលត្រូវ ។ ជាតិមនុស្សទោះខ្ពស់ទាប មិនះហាល
ភាពពីម៉ែឪ ពាក្យមនុស្សវែងជាងផ្លូវ ស្រូវច្រើនខូបខូប
អង្ករ ។ របស់ទ្រព្យហោកផ្លែ ទុកសំបែលែឲ្យល្អ អុង
អាងពាងក្រឡ ត្រដទិញកុំឲ្យខ្វះ ។ កើតមកខ្លួនជា
រាស្ត្រ ក្រប្រាក់មាសឲ្យមានខ្នាស សារពើរគ្រឿងប្រើ
ប្រាស ឲ្យមានចាស់ឲ្យមានថ្មី ។ ព្យូហៅដឹងកាំបិត ពន្លាក

ទិតបបវែងខ្លី ខ្សែសេះគោក្របី ឫស្សីផ្តៅកាប់សង្រែក ។
ការងាយកុំឲ្យក្រ អាក្រក់ល្អមានដោយខ្សែក ថ្ងៃនេះរបេះបាក់
បែក ស្អែកទំរើធ្វើជាធាប់ ។ ឈ្មោះការប្រើលើដី កុំបាំស្រើ
តឿនប្រើប្រាប់ ឲ្យមានគ្រប់ប្រដាប់ សំរាប់រាល់ឲ្យសល់ប្រើ ។
កុំខ្ជិលល្ងង់ខ្លៅពេក ឲ្យបេះដេកឲ្យបេះដើរ បេះសព្វគាប់ប្រ-
សើរ កុំចង់ហើរហួសភាពខ្លួន ។ បង់ក្តីឲ្យរៀនច្បាប់ រស់
នឹងស្លាប់ឲ្យបេះក្បួន បេះអ្វីបេះឲ្យត្បួន កុំបន្លំផ្សំនឹងគេ ។
កុំដេកចាំសំណាង កុំស្អេកស្អាងចាំបុព្វេ ខំរកកុំទំនេ រវៀន
រិះបេះឲ្យគ្រប់ ។ នឹង.ដើរស្វែងរកផល មិនទាន់ដល់កុំអាល
ឈប់ ឈានខ្លាំងពេកជំពប់ បើដេកយប់ឲ្យស្គាល់យាម ។
កុំដេកយូរទ្រមឹក លក់ហួសព្រឹកខុសទំនៀម តែភ្លឺឡើងភ្ញាក់
ភ្លាម ព្រហាមឡើង ក្រោកធ្វើការ ។ ជាតិមនុស្សទោះប្រុស
ស្រី រាស្ត្រមន្ត្រីជាធម្មតា ពេលព្រឹកតែងឧស្សាហ៍ ថ្ងៃក្តៅ
ល្ហោខ្ជិលល្អិតល្អឹង ។ បង់ធំទំពីតូច បើខ្លាចខូចកុំធាប់
ទំង ការអ្វីឲ្យបេះប្លឹង កុំប្រឹងជុះតាមដំរី ។ កុំចង់ខ្ពស់ស្មើ
មេឃ កុំឲនពេកអាប់រាសី ទោះដើរនិយាយស្តី លៃឲ្យ

ល្មមតែគួរសម ។ យល់ឆ្ងាយកុំណាយគិត ទោះយល់ជិត កុំអាលខំ មិនដាក់មើលឲ្យបំ ក្រែងប្រឡឹសជាខ្មៅ ។ ទំលាប់ធំជាងច្បាប់ បើរៀនត្រាប់កុំត្រាប់ខ្លៅ ត្រាប់ប្រាជ្ញអាចប្រដៅ ស្ដីកូនចៅស្ដីឲ្យស្មោះ ។ ស្មឹងស្មឹលសីលរបៀន ឲ្យគេរៀនកុំឲ្យអស់ ស្រឡាញ់កុំញ៉ោះញ៉ោះ បើខឹងទាស់កុំឲ្យទាយ ឆ្កែព្រុះកុំព្រួយពេក ឃើញឆ្កែដេកកុំមើលងាយ កំណាប់ដប់សំពាយ កុំនិយាយប្រាប់សំឡាញ់ ។ សំឡឹងមើលឲ្យសព្វ បើនឹងស្អប់កុំអាលបាញ់ ក្ដីឈ្នះគេបុះបាញ់ កុំខ្នាញ់តាមផ្ដន្ទាទៀត ៗ បើខឹងកុំរំលោភ បើនឹងល្មោភឲ្យល្មមមាត កុំល្មោភក្រែងភ្លាត់ស្នៀត វាតព្វេសវង្សផុងគំនិត ។ កុំណើតអាក្រកល្អ មាននឹងក្រមកពីអិត ពីកាលបុព្វេពិត ងងិតពេកមើលមិនយល់ ។ ដាំដូងឲ្យខំថែ បង់ស៊ីផ្លែឲ្យដុតគល់ បើជូនសំណាងដល់ រវល់តែស៊ីឆ្ងាញ់ពីសារ ។ ប្រាជ្ញប្រិតប្រៀនប្រដៅ ចូរកូនចៅពិចារណា រំពឹងក្នុងប្រាជ្ញា ត្រាយបញ្ហានេះឲ្យដឹង ។ នេះច្បាប់កិរកាលថ្មី អស់សេចក្ដីតែប៉ុណ្ណឹង កូនប្រុសអ្នកខំប្រឹង សំឡឹងចាំតទៅមុខ ។ ពីឆ្នាំប

តទៅ ខ្ញុំធ្វើស្រែដាក់បង្រិក អាស្រូវពាក្យអាពុក ទុកឲ្យកូនចៅគ្រប់គ្នា ។ អាពុកកាន់តែចាស់ ស្ដាយខ្លួនណាស់ចូលជរា ពាក្យពិត ៥០០ឃ្លា ជាស្ងួរេចម្លេះឯងហោង ។ ៚

អ្នកព្រះភិរម្យល្បើ លើកច្បាប់ថ្មីអស់ល្បៀត់ល្បង ឈ្មោះអ៊ូហៅង៉ុយផង ចង់ជាច្បាប់សំរាប់ជន ។ ខ្ញុំសូមផ្សងសច្ចា កើតជាតិណាសូមមានបុណ្យ មូលកូនមូលប្រពន្ធ ធនសម្បត្តិសប្បាយ ។ ស្ពាលាក្រលំបាក សូមជៀសចាកបត្តរាបាយ សូមល្អពង្សរូបកាយ កុំឲ្យឆ្ងាយពីព្រះពុទ្ធ ។ ប្រាជ្ញាកុំទើសទាល់ បេះអាបិធមិឲ្យមាំមុត សូមជាប់សីលបរិសុទ្ធិ រំលត់ទុក្ខសោកភោគភ័យ ។ អានិសង្សបុណ្យខ្ញុំបាន សាងបុគ្គានក្នុងលោកីយ៍ សម្បត្តិសួគ៌ាលៃ កុំបីឃ្លាតរវាតវែងឆ្ងាយ ។ ពីជាតិនេះទៅមុខ មូលអាពុកជួបមូលម្ដាយ បងប្អូនកុំខ្វាត់ខ្វាយ អធិប្បាយចែងចប់ឯរំ ។ ៚

ECOLE FRANÇAISE
BIBLIOTHÈQUE